# មរណៈស្នេហា

ស្នេហាផ្អែមល្ហែម តើមាននរណាមិនចង់ស្គាល់រសជាតិ?
តែស្នេហ៍លើលោក មានជួបមានឃ្លាត មានសប្បាយ មានទារុណ ...
បើបែបនេះតើមនុស្សយើងគួរបណ្ដាក់ទុនមនោសញ្ចេតនា
លើមុខជំនួញស្នេហាយ៉ាងណាដែរ?
មរណា តើមាននរណាចៀសផុត? តែពេលប្រឈមមុខនឹងមរណៈ
អ្នកណាក៏តក់ស្លុត រន្ធត់សោកសង្រេង ...
បើអ្នកមានឱកាសបានដឹងពីកាលកំណត់ស្លាប់រស់របស់ខ្លួនឯង
តើអ្នកនឹងចាត់ចែងខាសនាអនាគតរបស់អ្នកយ៉ាងណាដែរ?

ខ្សែនេត្រាវេញត្របាញ់រកគ្នា បេះដូងទាំងគូអន្ទងទាមទារ
ចង់នែបនិត្យកៀកកើយ តែត្រូវម្ចាស់រារាំងមិនព្រមបណ្ដោយ
ឱ្យបានជួបជិត ... ទម្រាំតែពួកគេហ៊ានទទួលស្គាល់ការពិត
ព្រហ្មលិខិតក៏មកកម្រិតឱ្យព្រាត់គ្នា។
**មរណៈស្នេហា** លាតត្រដាងពីសំណាញ់វាសនា ត្បាញប្រទាក់ក្រលា
ចេញពីសរសៃរស្ទូតនៃជីវិត បង្កើតបានជាអន្ទាក់ដួងចិត្ត បង្ខិតបង្ខំ
នារីម្នាក់ឱ្យធ្លាក់ខ្លួនជាទាសករលោកិយ ហ៊ានតតាំងលះបង់គ្រប់អ្វីៗ
ដើម្បីឱ្យប្រាណបានភប់ប្រសព្វនឹងបុគ្គលដែលខ្លួនប្រាថ្នា...ទោះជាដឹងថា
ការជួបគ្នាមានវេលាតិចខ្លីយ៉ាងណាក្ដី!
តើ **មរណៈស្នេហា** អាចផ្ដល់ជាគតិយ៉ាងណាខ្លះ?
មានតែអ្នកអានទេ ទើបអាចសម្រេចចិត្តបាន។

*Love & Loss*

# ប្រលោមលោក

# មរណៈស្នេហា

(អមដោយរូបភាព)

## ភាគទីមួយ



រៀបរៀងដោយ៖

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី

# For My Sister

# ឥទ្ធិពលស្នេហ៍
# (Woman in Love)



រថយន្តតូចម៉ាកភស្គដ៏ទំនើប ពណ៌ក្រហម ស្អាតច្រឡឹង មួយគ្រឿង កំពុងបរយ៉ាង សន្សឹមៗតាមផ្លូវមួយចូលទៅក្នុងភូមិ **វាលស្បូវ** ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទីក្រុងភ្នំពេញ។ មួយរយៈក្រោយមក រថយន្តភស្គបានមកឈប់សំចតនៅក្បែររបង នៃគេហដ្ឋានចំណាស់មួយសង់តាមរបៀបខ្មែរកាត់បារាំង ដំបូលប្រក់ក្បឿងស្រកាលិញមានដុះស្នឹមឡើងពណ៌ខ្មៅ ដូចដំបូលព្រះវិហារ។ គ្រាន់តែមួយក្រលេកភ្នែក អ្នកណាក៏អាចសន្និដ្ឋានបានថា នេះជាគេហដ្ឋានដែលបានឆ្លងកាត់មនុស្សជាច្រើនជំនាន់មកហើយ ហើយថែមទាំងបានគេចផុតអំពីការបំផ្លិចបំផ្លាញរបស់សង្គ្រាមនិង ភាពវឹកវរនានាដែលធ្លាប់កើតមានជាបន្តបន្ទាប់នៅក្នុងប្រវត្តិសាស្ត្រស្រុកយើង។

នៅក្នុងរថយន្តមានមនុស្សតែម្នាក់ប៉ុណ្ណោះ គឺអ្នកកាន់ចង្កូតដែលជានារីប្រកបដោយវង់ភ័ក្ត្រស្រស់ត្រកាល ថ្វីបើនាងមិនមែនស្ថិតក្នុងជំពូកយុវវ័យក្មេងខ្ចី តែរូបសម្ផស្សកល្យាណីរូបនេះមានសភាពទាក់ទាញយ៉ាងខ្លាំងសម្បើម ... និយាយរួម គឺនាងស្រស់ស្អាតប្លែកភ្នែកអ្នកជាយក្រុង គួរឱ្យជញ្ជក់មាត់សរសើរដូចជារថយន្តដ៏ទំនើបដែលនាងកំពុងបញ្ជានេះដែរ!

ទោះជាយានជំនិះឈប់ស្ងៀមលែងមានចលនាអស់ពីជាយូរ តែនារីយើងនៅទុកម៉ាស៊ីនវាឱ្យរត់តាមយថាកម្ម ឯហត្ថានាងទាំងគូនៅកាន់ចង្កូតយានយ៉ាងមាំ ហាក់ខ្លាចឧបករណ៍រាងរង្វង់មួយហ្នឹងរបូតពីដៃចេញទៅបាត់ ... ម៉ាស៊ីនចម្រៀងក្នុងរថយន្តកំពុងបន្លឺនូវសំនៀងដ៏ពិរោះរណ្ដំនៃសិល្បការិនីប្រចាំប្រទេស ប៉ុន្តែអ្នកស្ដាប់ហាក់ពុំបានឮឬចាប់អារម្មណ៍បន្តិចទេ នេត្រាដ៏ភ្លឺថ្លារបស់នាងទាំងទ្វេកំពុងតែរេចុះរេឡើងសម្លឹងមិនដាក់ទៅកាន់គេហដ្ឋានចំណាស់ ដែលសំងំលាក់ខ្លួនធ្វើហីនៅពីក្រោយទីធ្លានិងសួនច្បារដែលមានបុប្ផាជាតិជាច្រើនប្រភេទដុះចម្រុះគ្នា ខ្លះតូចខ្លះធំ ខ្លះទាបខ្លះខ្ពស់ ខ្លះឈរត្រង់ខ្លះវាងរោងគេងង ខ្លះទម្លាក់ខ្លួនរយីងរយោងពីបង្កង ខ្លះផ្ញៃខ្លះផ្កា ខ្លះមានតែស្លឹកពណ៌បៃតងស្រងាត់ កំពុងតែបញ្ចេញសម្ផស្សបង្អួតដាក់គ្នាយ៉ាងឥតសណ្ដាប់ធ្នាប់ លាយឡំនឹងពពួកស្មៅឥតប្រយោជន៍ដែលប្រជែងលូតលាស់ក្នុងសួនយ៉ាងគឃ្លើន។ បើគេវាសខ្សែភ្នែកហួសពីមុខផ្ទះទៅបរិវេណខាងចំហៀងផ្ទះនិងក្រោយផ្ទះម្ដង នោះគេនឹងបានឃើញថាគេហដ្ឋានចំណាស់នៅហ៊ុមព័ទ្ធផងដែរដោយរុក្ខជាតិហូបផ្លែតូចធំជាច្រើនទៀត ដូចជាចេក ល្ហុង ស្វាយ ល្មុត ត្របែក ខ្នុរ ដូង ...។ល។

នារីក្នុងរថយន្តភស្គលើកខ្នងដៃម្ខាងជូតញើសលើថ្ងាស បើទោះបីជាម៉ាស៊ីនត្រជាក់នៃយាន កំពុងតែដំណើរការបញ្ចេញចំហាយដ៏ត្រជាក់ស្រឹបស្ទើរព្រឺឆ្អឹងខ្នងទៅហើយក្ដី ... នាងហាក់មានអាការៈរសាប់រសល់ ខ្វល់ខ្វាយរកថាមិនត្រូវ។ អ្នកធ្វើដំណើរឆ្លងកាត់តាមផ្លូវនេះ មានចាស់មានក្មេង មានស្រីមានប្រុស សុទ្ធតែលួចចោលភ្នែកដោយក្ដីចាប់អារម្មណ៍ទៅលើរថយន្តនិងនារីប្លែកមុខដែលនៅអង្គុយសំកុកក្នុងឡានមិនព្រមចេញទៅណា ... ពួកគេគិតតែក្នុងចិត្តរៀងខ្លួនថា ប្រហែលជានាងកំពុងតែរង់ចាំនរណាម្នាក់ ឬនាងមករកនរណាម្នាក់នៅក្នុង **ផ្ទះបុរាណ** តែមិនហ៊ានចូលទៅ។

និយាយពីផ្ទះបុរាណ (ជាឈ្មោះអ្នកភូមិធ្លាប់ហៅតៗតាមគ្នា) ពួកអ្នកស្រុកម្ដុំនោះ មានភាគតិចណាស់ដែលមិនព្រឺក្បាលកាលណាគេរំឭកដល់ឈ្មោះឬឆ្លងកាត់តាមផ្លូវមុខផ្ទះចាស់ចម្លែកនោះ ... តាំងពីចាស់សក់សរហូតដល់ក្មេងបៀមដៃ សុទ្ធតែមានជំនឿអួមអោមតាមគ្នាថា **ផ្ទះបុរាណមានខ្មោចកាន់។** ជាង៣០ឆ្នាំហើយ ដែលផ្ទះបុរាណនេះស្ថិតក្នុងសភាពដែលគេបោះបង់ចោល យូរៗទើបគេឃើញមានរថយន្តឬមនុស្សចេញចូលម្ដងម្កាល។ ពេលថ្មីៗនេះ ដូចជាមានបុរសម្នាក់មកស្នាក់នៅក្នុងផ្ទះបុរាណ តែមិនសូវមាននរណាដឹងច្បាស់ថាបុរសនោះជាអ្នកណាទេ ព្រោះម្ចាស់ផ្ទះឬអ្នកស្នាក់អាស្រ័យនៅក្នុងផ្ទះបុរាណពុំសូវបង្ហាញមុខមាត់ឬរាប់រកអ្នកភូមិផងរបងជាមួយឡើយ។ បើកុំតែគេបានឃើញពន្លឺភ្លើងអគ្គិសនីចាំងចេញមកតាមបង្អួចនៃគេហដ្ឋាន ក្នុងពេលរាត្រី ម៉្លេះគេពិតជាពិបាកជឿថាផ្ទះបុរាណមានមនុស្សរស់នៅណាស់។

*បែរមកនារីនៅក្នុងរថយន្តវិញ នាងនៅតែអង្គុយសញ្ជប់សញ្ជឹងហាក់មិនដឹងថាត្រូវ ធ្វើអ្វីឱ្យមិនដាច់ស្រេចសោះ ... តែបន្ទាប់ពីដកដង្ហើមធំយូរៗប៉ុន្មានដងមកនាង ស្រាប់តែពន្ធត់ម៉ាស៊ីនយាន ចាប់ទាញកាបូបពីលើពូកឡានមកពាក់លើស្មា ដៃម្ខាងស្រវាយកសឺមីកិច្ចការដែលមុននេះនាងបានដាក់កាបូបពីលើ មកកាន់ រួចហើយនាងទាញគន្លឹះ រុញទ្វាឡានឱ្យបើកឃ្វាំងឡើង។ ក្រោយពេលនាំរាងកាយដ៏ល្អល្អះរបស់នាងចេញមកដល់ក្រៅ នារីចុចម៉ាស៊ីនទូរបញ្ជាឱ្យចាក់សោរទ្វារយានព្ធសួរក្ញឹកសិនមុននឹងទម្លាក់ឧបករណ៍តូចដែលនៅជាប់នឹងសោរឡានស្រាប់ ទៅក្នុងកាបូបនាងប្ញុក។*



*នារីរូបល្អក៏ចរយាត្រាទៅកាន់មុខទ្វាររបងនៃគេហដ្ឋានបុរាណ។ នាងឈរធ្វើរេរានៅទីនោះម្តង ប្រហែលជាមិនដឹងធ្វើយ៉ាងណាព្រោះនៅខាងក្រៅរបងគ្មានកណ្តឹងអគ្គិសនីសម្រាប់ចុចផ្តល់ដំណឹងនៃការមកដល់របស់ភ្ញៀវដូចផ្ទះគេទូទៅឡើយ រីឯបរិវេណក្នុងរបងវិញ មានសភាពស្ងាត់ជ្រងំ ពុំឃើញមានស្រមោលមនុស្សម្នាដល់ម្នាក់សោះ បើបែបនេះ តើធ្វើម្តេចនាងអាចចូលទៅខាងក្នុងបាន?*

*នារីពិនិត្យឃើញថា ទ្វាររបងឥតមានចាក់សោរទេ គឺមានតែគន្លឹះដារនុកដាក់ពីខាងក្នុង ដែលមើលតាមទំនង នាងប្រហែលជាអាចលូកដៃទៅទាញឱ្យរបូតចេញដោយងាយ។ មាណវីយើងនៅឈរឈ្ងោកដីធ្វើត្រេះត្រុះអស់មួយសន្ទុះធំ ទើបនាងងើបមុខសម្លឹងទៅកាន់តួគេហដ្ឋានបុរាណជាថ្មីព្រមជាមួយនឹងសម្តីពោលរអ៊ូរឱ្យឺបៗម្នាក់ឯងផង "តើយើងធ្វើនេះត្រូវទេ? បើបកក្រោយ គឺនៅមានពេលនៅឡើយ!..." ប៉ុន្តែសំលេងមួយដែលបានញាំញីចិត្តនាងអស់ជាច្រើនថ្ងៃមកហើយ បានស្រែកជំទាស់ភ្លាមថា៖ "ឆាប់បើកទ្វារចូលភ្លាមទៅ! មិនត្រូវរារែកទេ! បើឯងបកក្រោយវិញ ឯងនឹងបាត់បង់ឱកាសល្អនេះជារៀងរហូត! យ៉ាងណាក៏បានជាមកដល់ទៅហើយ ត្រូវតែសាកល្បង! ត្រូវតែប្រថុយ!..."*

*នៅទីបំផុត សំលេងក្នុងចិត្តក៏មានជ័យជំនះលើភាពរួញរារបស់នាង នារីលូកដៃតាមប្រលោះចម្រឹងទ្វារ ទាញអង្កៀកគន្លឹះយ៉ាងសន្សឹមៗ។ បន្ទាប់ពីចោលសំលេងង៉េតង៉ត់ស្រាលៗបី បួនដង្ហើមមក គន្លឹះទ្វារក៏របូតឃ្វាំង! នារីយើងរុញទ្វារឱ្យចំហធំ ល្មមតែនាងត្បុលខ្លួនចូលទៅខាងក្នុងបាន រួចនាងយកខ្នងរុញទ្វារបិទផ្អឹបចូលគ្នាវិញ តែនាងមិនបានដាក់គន្លឹះវិញទេ។ បានចូលផុតរបងផ្ទះពេលណា បេះដូងនារីលោតញាប់រន្ទឺនស្ទើរធ្លាយចេញពីទ្រូង នាងវេខ្សែភ្នែកសម្លឹងពិនិត្យបរិយាកាសជុំវិញខ្លួនដោយអារម្មណ៍ញាប់ញ័រ។ ញើសចាប់ផ្តើមដណ្តើមគ្នារត់ចេញមកស្រិបៗ ធ្វើឱ្យថ្ងាសនាងសើមជោក បាតដៃបាតជើងត្រជាក់ល្ហុក ដង្ហើមផុតៗ។ មាណវីលើកដៃធ្វេងទប់ទ្រូង លួចត្អូញត្អែរក្នុងចិត្ត "ឱ អញអើយ ប្រហែលជាត្រូវគាំងបេះដូងស្លាប់ក្នុងពេលនេះទេដឹង? តើគួរទៅមុខទៀតឬក៏បកក្រោយវិញ?"*

*សុរិយាពេលព្រឹកវេលាម៉ោងប្រមាណជាដប់ ចោលរស្មីត្រចះលើធម្មជាតិ។ កាលពីយប់មិញមានភ្លៀងមួយមេធំ តែថ្ងៃនេះមេឃាខៀវស្រលះលម្អដោយពពកដុំៗមានពណ៌សក្បុសដូចសំឡី។ នារីងើបភ័ក្ត្រសម្លឹងផ្ទៃវេហាស៍ដ៏ធំធេង ... នាងដកដង្ហើម វែងៗយកខ្យល់បំពេញសួត ទើបដាច់ចិត្តបោះជំហានសន្សឹមៗសំដៅទៅរកទ្វារនៃគេហដ្ឋាន ធ្វងកាត់តាមបណ្តោយផ្លូវទីធ្លាមុខផ្ទះដែលក្រាលគ្របទៅដោយស្មៅកុក្ខជាតិទុំជ្រុះចាកមែកមានចាស់មានថ្មី។ បរិវេណខាងក្រៅផ្ទះមានសភាពស្ងាត់ជ្រងំដូចទីស្មសាន មានតែសំលេងបក្សាបក្សីចរចារកំដរបរិយាកាសគួរស្រងេះស្រងោចពន់ពេក។ សន្ទឹកទ្វារឈើដ៏ធំគ្រាក់ទាំងពីរផ្ទាំងបិទជិតឈឹង តែសន្ទឹកបង្អួចភាគច្រើនបើកចំហពាក់កណ្តាលឬចំហពេញទំហឹងតែម្តង។ ជំនោរត្រសៀកៗបានបក់ផាត់ស្បែរាំងននខ្វះឱ្យរេរាំពត់ពែនខ្លួនយ៉ាងទន់ភ្លន់ ហាក់ជួយផ្តល់ជាកម្លាំងចិត្តដល់នារីយើងឱ្យខំបង្កើនល្បឿនដើម្បីឱ្យ ឆាប់ទៅដល់គោលដៅ។*

*នារីរូបល្អបានមកដល់មាត់ទ្វារផ្ទះហើយ នាងឈរសម្រួលឥរិយាបថបន្តិច ដកដង្ហើមធំមួយយូរទៀត ទើបលើកហត្ថគោះថ្នមៗទៅលើផ្ទាំងសន្ទឹកទ្វារដែលច្នៃ ចេញពីសាច់ឈើយ៉ាងក្រាស់ មានក្បាច់ក្បូរដ៏វិចិត្រ តុក! តុក! តុក! ... ស្ងាត់ច្រៀប!*

*បន្ទាប់ពីរង់ចាំចម្លើយដោយឥតប្រយោជន៍អស់ពីរ-បីនាទីមក នារីយើងបញ្ចេញកម្លាំងគោះទ្វារខ្លាំងជាងមុន ... តែលទ្ធផលដូច*

*ដើម គឺស្វាត់ច្រៀបដដែល! លើកនេះនាងលែងរវល់ច្រើន ក៏ក្ដាប់ដៃទូងទ្វារយកជ័យតែម្ដង ក្អូង! ក្អូង! ស្រាប់តែរំពេចនោះ សន្ទឹកទ្វារក៏របើកក្រាក ហាក់ដូចចេះបើកដោយឯកឯង ... នារីមិនបានរង់ចាំវត្តមានម្ចាស់ផ្ទះចេញមកគួរសមសិនទេ នាងលើកដៃរុញបន្ថែមឱ្យទ្វារ បើកចំហយ៉ាងធំពេញទំហឹង រួចហើយនាងបោះជំហានយ៉ាងក្លាហានចូលទៅក្នុងគេហដ្ឋាន។*

*គ្រាន់តែចូលផុតមាត់ទ្វារ កល្យាណីក៏ឈមមុខនឹងបន្ទប់ទទួលភ្ញៀវដ៏ធំទូលាយ។ ពន្លឺព្រះអាទិត្យដែលជះចូលតាមទ្វារនិងបង្អួចចំហទាំងប្រាំ អាចឱ្យនាងមើលឃើញទិដ្ឋភាពខាងក្នុងយ៉ាងច្បាស់។ ផ្ទុយស្រលះពីសភាពខាងក្រៅ ដែលហាក់ដូចជាផ្ទះត្រូវគេបោះបង់ចោល បន្ទប់ទទួលភ្ញៀវមានលក្ខណៈស្រស់ស្អាត និងមានរបៀបរៀបរយគួរគាប់ភ្នែក។ ការតុបតែងនិងគ្រឿងសង្ហារឹមមានបែបផែនជាខ្មែរ គឺគ្មានសាឡុងទន់ៗបែបទំនើបទេ មានតែកៅអីឈើរាងចំណាស់ៗចំនួនប្រាំ គឺកៅអីវែងអាសនៈមួយនិងកៅអីមានភ្នាក់ដៃតូចៗចំនួនបួន នៅអមជុំវិញតុទទួលភ្ញៀវមួយរាងបួនជ្រុងទ្រវែង។ រំលងពីទីនោះប្រហែលជាបី-បួនជំហាន មានគ្រែធំមួយមានផ្ទៃរលីងរលើបរលោងស្រិល។ ពិនិត្យតាមលំនាំសាច់ឈើនិងក្បាច់ចម្លាក់ គេអាចនឹកគិតថាតុ កៅអី និងគ្រែទាំងនេះ គឺរចនាចេញពីឈើនាងនួន ហើយប្រហែលជាច្នៃ ចេញពីសាច់ឈើតែមួយនិងចេញពីទឹកដៃជាងតែម្នាក់។*






*វត្ថុសិល្បៈបែបបុរាណខ្មែរត្រូវគេដាក់តាំងយ៉ាងមានរបៀបនៅខាងក្រៅខ្លះនិងនៅក្នុងទូរតាំងខ្លះ ជាសញ្ញាបញ្ជាក់ថាម្ចាស់ផ្ទះជាអ្នកបុរាណនិយម និងប្រហែលជាមនុស្សមានចិត្តអភិរក្សវប្បធម៌ខ្មែរយ៉ាងមុតមាំ*




*ថែមទាំងអ្នកចូលចិត្តអានផងដែរ ព្រោះនៅក្បែរទូរតាំងវត្ថុសិល្បៈ មានទូរឈើចំណាស់មួយធំផ្ទុកដោយសៀវភៅជាច្រើនប្រភេទ មានចាស់មានថ្មី។*

*នៅខាងស្ដាំដៃនៃទីទទួលភ្ញៀវ គឺទីទទួលទានអាហារដែលមានតុរាងពងក្រពើមួយ និងមានកៅចំនួនប្រាំបីនៅព័ទ្ធជុំវិញ។ ទីទទួលភ្ញៀវនិងទីទទួលទានអាហារខ័ណ្ឌចេញពីគ្នាដោយជណ្ដើរកាច់សម្រាប់នាំដំណើរទៅកាន់ជាន់ខាងលើនៃគេហដ្ឋាន។*

*បន្ទាប់ពីវេខ្សែចក្ខុគយគន់ការរៀបចំក្នុងគេហដ្ឋានបុរាណដោយក្ដីរំភើបមួយគ្រាមក នារីក៏បន្លឺវាចាលាន់ខ្ទាំងៗ "សួស្ដី! មានអ្នកណានៅផ្ទះទេ?!..."*

*សំលេងលាន់គ្រអៅបែបនេះ ទោះជាមនុស្សថ្លង់ល្មមៗក៏ស្ដាប់ឮដែរ តែនេះបែរស្ងាត់ច្រៀបដាងពេលនៅខាងក្រៅផ្ទះទៅទៀត។ ស្រស់ឆោមយង់ចង់ចិញ្ចើមបន្តិច ទំនងជាមានចិត្តគ្នាន់ក្នាញ់ដោយគ្មាននរណាឆ្លើយតបមកនាងវិញ ហើយក៏តាំងរអ៊ូតិចៗចេញមក "អស្ចារ្យមែន! ដំណើចរបៀបនេះ បើមានចោរចូលផ្ទះ មិនបោសស្អាត អស់រលីងទេឬ? មើលចុះ សុទ្ធតែរបស់មានតម្លៃ ... យីឬមួយដឹងថាយើងមក ទើបធ្វើជាដំណើច មិនព្រមចេញមុខមកគួរសម ... គិតថាធ្វើយ៉ាងហ្នឹងអាចបញ្ឈឺយើង ឱ្យយើងដើរចេញទៅវិញដោយស្រួលៗ? មិនងាយបែបនោះទេ កុំសង្ឃឹម!"*

*នារីលោស់វាចាខ្ទាំងៗឡើងមកម្ដងទៀត "មនុស្សនៅផ្ទះទេ? មានមនុស្សទេ?!" រួចនាងទម្លាក់សំលេងពោលខ្សឹបៗ "ឬក៏ក្លាយជាខ្មោចអស់ទៅហើយ? ទោះជាយ៉ាងណាក៏មិនគួរខ្វះការគួរសមដល់ថ្នាក់នេះដែរ..." ស្រដីហើយ មាណវីក៏បោះជំហានចូលកាន់តែជ្រៅទៅក្នុងបន្ទប់ទទួលភ្ញៀវ។ នៅក្បែរបង្អួចដែលបែរចំទៅរកសួនច្បារខាងក្រៅផ្ទះ មានកៅអីឈើប៉ាក់ពើកមួយឈមមុខទៅរកកូនតុដែលមានទ្រពែងកាហ្វេមួយនិងសៀវភៅពីរបីក្បាល។ នារីដើរទៅជិតកូនតុ នាងឈ្ងោកមុខមើលទៅឃើញក្នុងពែងមានកាហ្វេខ្មៅជាងកន្លះពែង នាងលួចចោលភ្នែកមើលទៅទំព័រសៀវភៅមួយក្បាលដែលត្រូវគេបើកចំហទុក ចោលនៅក្បែរពែងកាហ្វេ ឃើញថាជាអត្ថបទប្រលោមលោកជាភាសាអង់គ្លេស។ កស្តុតាងនៅលើកូនតុជាសញ្ញាបញ្ជាក់ថាម្ចាស់កាហ្វេនិងសៀវភៅប្រហែលជាមិនទៅណាឆ្ងាយឡើយ។ នារីរូបស្រស់បែរមុខចេញពីកូនតុ ហើយបោះជំហានមកឈរនៅពីមុខជណ្ដើរម្ដង នាងជ្រួញចិញ្ចើមសញ្ជឹងគិត "តើយើងគួរធ្វើយ៉ាងណាទៀតហ្អេះ ... ឬក៏ទន្ទ្រានឡើងទៅលើផ្ទះមួយជាន់ទៀត?"*

*ក្នុងពេលដែលនារីយើងកំពុងតែត្រិះរិះពិចារណាថាគួរឬពុំគួរចូលទៅលុកលុយ កន្លែងណាទៀតក្នុងផ្ទះ ស្រាប់តែនាងហាក់បាន ឮសូរសំលេងថ្ងូរតិចៗ ... ស្រស់ស្រីឈរទ្រឹងខំប្រឹងផ្ទៀងត្រចៀកស្តាប់ជាបន្ត ... សំលេងថ្ងូរក៏លាន់តិចៗចេញមកទៀត។ សេចក្តីភ័យខ្លាចបានលបចូលមកក្រសោបបេះដូងនារីរូបល្អ តែការជឿងធ្ងល់និងភាពអស្មិមានះដ៏មាំមួនក៏បានមកសណ្ឋិតក្នុងចិត្តនាងដែរ ហើយថែមទាំងប្រទាញនាងឱ្យធ្វើដំណើរយឺតយ៉ាងប្រុងប្រយ័ត្នតម្រង់ទៅកាន់ប្រភពសំលេង។ នារីយាត្រាឆ្លងកាត់តាមបន្ទប់អាហារឆ្ពោះទៅកាន់បន្ទប់មួយទៀតដែលស្ថិតនៅប៉ែកខាងក្រោយផ្ទះ ... ឆ្លងផុតបន្ទប់អាហារពេលណា នារីដើរចូលទៅតាមទ្វារដែលបើកចំហស្រាប់ នាងក៏បានចូលមកដល់បន្ទប់ចំអិនអាហារ ប៉ុន្តែនាងគ្មានពេលធ្វើការគយគន់ទិដ្ឋភាពក្នុងបន្ទប់នេះដូចពេលមុនឡើយ ព្រោះរូបភាពនៅចំពោះមុខនាង បានធ្វើឱ្យនាងតក់ស្លុតរន្ធត់ចិត្តជាខ្លាំង នុះន៎! បុរសម្នាក់កំពុងតែដួលដេកផ្កាប់មុខនៅលើកម្រាលឥដ្ឋ នៅពីមុខទូរទឹកកកពណ៌សមួយ។*



*នៅលើឥដ្ឋ កន្លែង ដែលបុរសផ្តេកក្បាល មានសុទ្ធតែអំបែងកែវច្រូងច្រាង។ បំណែកអំបែងនិងក្បាលមនុស្សកំពុងតែដេកត្រាំក្នុងថ្លុកឈាមក្រហមឆ្អៅជាមួយគ្នា។ បុរសរងគ្រោះទំនងជាកំពុងតែខំប្រឹងយោងអាត្មាដើម្បីក្រោកឡើង តែគេអាចត្រឹមតែកម្រើកខ្លួនតិចៗ និងបញ្ចេញសំលេងថ្ងូរស្រាលៗប៉ុណ្ណោះ។*

*មិនបង្អង់យូរ នារីយើងស្ទុះចូលទៅលុតជង្គង់ជិតជើងជនរងគ្រោះ ហើយស្រែកសួរដោយសំលេងញ័ររន្ធត់ "រតនៈមង្គល គឺលោកមែនទេ? តើលោកកើតអី?"*

*តែអ្នកដែលនាងសួរ ឆ្លើយតបវិញដោយសំលេងថ្ងូរតិចៗដដែល។ ដោយមិនគិតពីអ្វីក្រៅពីក្តីបារម្ភដល់អាយុជីវិតរបស់បុរសរងគ្រោះ មាណវីគ្រវាត់សឺមីដែលកាន់នៅដៃចោលមួយរំពេច ហើយស្ទុះចូលទៅចាប់ត្រលប់កាយជនរងគ្រោះ រួចនាង លើកទ្រត្រកងក្បាលបុរសរងគ្រោះចេញពីគំនរអំបែងនិងថ្លុកលោហិតដ៏រាវកក្វាក់ ដែលទំនងជាកើតឡើងដោយសារឈាមលាយនឹងទឹក។*

*នារីផ្តេកក្បាលបុរសរងគ្រោះឱ្យកើយលើដៃខាងឆ្វេងរបស់នាង ហើយខំស្រែកសួរទៀត "រតនៈមង្គល លោកយ៉ាងម៉េចទៅហើយ? តើមានរឿងអី?"*

*លើមុខបុរសដែលមានឈ្មោះថារតនៈមង្គល មានស្នាមដាច់ដោយធូតនឹងអំបែងកែវដោយអន្ទើ ប៉ុន្តែរបួសដែលគួរឱ្យព្រួយបារម្ភជាងគេ គឺស្នាមរយះប្រវែងកន្ទះចំអាម កាត់បញ្ឆិតពីចុងចិញ្ចើមខាងឆ្វេងទៅដល់គល់សក់កណ្តាលថ្ងាស ឈាមហូរភលៗចេញពីមុខរបួសឥតឈប់ ស្រោចស្រពមកលើភ្នែកនិងមុខមាត់របស់បុរសរងគ្រោះ មុននឹងហៀរធ្លាក់ទៅលើកអាវដែលសើមជោកដោយឈាមស្រាប់ ហើយជ្រាបទៅលើដៃរបស់នារីរូបស្រស់ទៀត។ បុរសរងគ្រោះមិនបានបញ្ចេញសំលេងថ្ងូរទៀតទេ គេហាក់ខំប្រឹងបើកភ្នែកសម្លឹងអ្នកកំពុងបីត្រកងខ្លួន តែត្របកភ្នែកនិងរោមភ្នែកដែលសើមជោកដោយលោហិតក្រហមឆ្អៅ បានត្រឹមតែកម្រើកញ័រៗព្រឹមៗបន្តិចប៉ុណ្ណោះ ប៉ុន្មានវិនាទីក្រោយមកភ្នែកទាំងពីរក៏បិទជិតឈឹង។ អ្នករបួសបាត់ស្មារតីទាំងស្រុងទៅហើយ ទោះជានារីខំប្រឹងអង្រួននិងស្រែកហៅគេខ្លាំងៗយ៉ាងណា ក៏គេលែងមានប្រតិកម្មតបតវិញ ក្បាលគេទន់រងៀករេទៅមកតាមតែកាយវិការចាប់អង្រួនរបស់នារីចំណូលថ្មី។*

*ស្រស់ស្រីភ័យណាស់ គិតតែចាប់អង្រួនដាស់បុរសគេងកើយដៃនាងជាបន្ត "រតនៈមង្គល លោកឆាប់បើកភ្នែកឡើង! ឆ្លើយនឹងខ្ញុំមក តើមានរឿងអី? ... រតនៈមង្គល លោកកុំបំភ័យខ្ញុំ! ឆាប់ដឹងខ្លួនឡើង!"*

*បន្ទាប់ពីដឹងថាទោះជានាងស្រែកដាស់គេយ៉ាងក៏ឥតប្រយោជន៍ មាណវីបែរមកយកចិត្តទុកដាក់ដល់របួសលើថ្ងាសរបស់គេវិញ។ នាងស្រវាបើកកាបូបដែលធ្លាក់នៅជិតខ្លួន ចាប់ទាញយកកូនកន្សែងមួយមកបត់ជាបីជាន់យ៉ាងរួសរាន់ ហើយដាក់ផ្ទប់ទៅលើមុខរបួសដើម្បីឃាត់ឈាម តែកូនកន្សែងពណ៌សបានប្រែក្លាយជាពណ៌ក្រហមបន្តិចម្តងៗយ៉ាងរហ័ស។ នារីភ័យតក់ស្លុតកាន់តែខ្លាំងមែនទែន មិនដឹងថាគួរធ្វើយ៉ាងណា ក៏តាំងស្រែកហៅឈ្មោះរតនៈមង្គលទៀត ម្តងនេះថែមទាំងយំផង។*

*លុះនៅតែឥតប្រយោជន៍ នាងរកែរក្នែកស្ទន់ស្ទោដែលដោកជាំដោយជលនេត្រមើលជុំវិញខ្លួន រួចក៏ប្រថុយស្រែករកជំនួយ "មានអ្នកណានៅជិតនេះទេ? ជួយផង! ជួយផង!..."*

*ក្រៅពីសំលេងខ្យល់បក់ស្លឹកឈើស្រិបៗនិងសំលេងសត្វបក្សាបក្សីយំចេចចាចនៅខាងក្រៅផ្ទះ នាងពុំបានទទួលការឆ្លើយតបអ្វីទៀតឡើយៗ អស់សង្ឃឹម នារីបន្ទឺដោយសំណោកខ្សឹបខ្សួល "ពុទ្ធោអើយ ... តើឱ្យខ្ញុំធ្វើយ៉ាងណា?"*



*រំពេចនោះ នាងស្រាប់តែស្វាងស្មារតីឡើង "មែនហើយ ហៅឡានពេទ្យ!... ម៉េចបានជាយើងភ្លើនឹកមិនឃើញបែបនេះ?! ..." ពោលរអ៊ូបណ្ដើរ នាងប្រវេប្រវារាវរកទូរស័ព្ទដៃនៅក្នុងកាបូបបណ្ដើរៗ ចាប់បានទូរស័ព្ទកាលណាមាណវីប្រញាប់ចុចលេខពិសេសដើម្បីហៅរថយន្តសង្គ្រោះៗ គ្រាន់តែបានឮសំលេងអ្នកទទួលទូរស័ព្ទភ្លាម នារីយើងស្រែកសុំឱ្យគេបញ្ជូនឡានពេទ្យនិងគ្រូពេទ្យមកផ្ទះកើតហេតុយ៉ាងរហ័ស។ លុះត្រាតែទទួលការបញ្ជាក់យ៉ាងមាំថា គេនឹងបញ្ជូនរថយន្តសង្គ្រោះឱ្យមកដល់ក្នុងពេល ឆាប់បំផុត ទើបមាណវីរូបស្រស់ចុចទូរស័ព្ទបិទវិញៗ នារីយើងហាក់មានអារម្មណ៍នឹងនរជាងមុនបន្តិច នាងឱនចុះសម្លឹងមុខបុរសដោយកែវភ្នែកសង្វេគ "ទើបតែខានជួបលោកប្រហែលមួយខែសោះ ហេតុអីលោកប្រែប្រួលដល់ថ្នាក់នេះ? លោកកុំកើតអីឱ្យសោះណ៎ា!..." បន្ទាប់មកនាងទាញកេសាបុរសវង់គ្រោះមកឱបផ្អឹបលើដើមទ្រូងមាត់ពោលរងំៗ ដូចគេកំពុងលួង លោមក្មេងតូច "រតនៈមង្គល លោកមិនអីទេ ... បន្តិចទៀតឡានពេទ្យមកដល់ហើយ ... លោកទ្រាំបន្តិចណ៎ា ... បន្តិចទៀតអស់អីហើយ..."*

*តាំងពីនាងបានឈានចូលមកដល់ក្នុងផ្ទះបុរាណនេះ គិតទៅប្រហែលមិនដល់ដប់ប្រាំនាទីផងទេ ប៉ុន្តែនារីមានអារម្មណ៍ថានាងបានអង្គុយចាំក្នុងផ្ទះបាយដ៏ស្ងាត់ជ្រងំនេះអស់រាប់ម៉ោងទៅហើយ ទម្រាំតែនាងបានឮសូរសំលេងស៊ីរ៉ែនរបស់រថយន្តសង្គ្រោះដែលកាន់តែរំកិលជិតមក ...ៗ*



## Woman in Love

Life is a moment in space
When the dream is gone
It's a lonelier place
I kiss the morning goodbye
But down inside you know
We never know why

The road is narrow and long
When eyes meet eyes
And the feeling is strong
I turn away from the wall
I stumble and fall
But I give you it all...

I am a woman in love
And I do anything
To get you into my world
And hold you within
It's a right I defend
Over and over again
What do I do?



With you eternally mine
In love there is
No measure of time
We planned it all at the start
That you and I
Would live in each other's heart

We may be oceans away
You feel my love
I hear what you say
No truth is ever a lie
I stumble and fall
But I give you it all

I am a woman in love
And I'm talking to you
Do you know how it feels?
What a woman can do
It's a right that I defend
Over and over again......

**Artist: Barbra Streisand**